参考様式第１-14 号（規則第 13 条第２項第２号関係）　（日本産業規格Ａ列４）
ទម្រង់យោងលេខ1-14 (ទាក់ទងនឹងបទបញ្ញាប្រការ13 កថាខណ្ឌទី2 ចំណុចលេខ2)　(ស្តង់ដាឧស្សាហកម្មជប៉ុន A4)

# 石綿を含む建材等が使用されている建築物等の解体等の業務に従事する場合の留意点や補償制度等について
# អំពីចំណុចត្រូវយកចិត្តទុកដាក់និងប្រព័ន្ធសំណងជាដើមក្នុងករណីបំពេញការងារដូចជារុះរើជាដើមនូវសំណង់ជាដើមដែលប្រើប្រាស់សម្ភារៈសំណង់ជាដើមដែលមានផ្ទុកសារធាតុអាបេស្តូស

## １　石綿を含む建材等が使用されている建築物等の解体等の業務に従事する場合の留意点について

## អំពីចំណុចត្រូវយកចិត្តទុកដាក់ក្នុងករណីបំពេញការងារដូចជារុះរើជាដើមនូវសំណង់ជាដើមដែលប្រើប្រាស់សម្ភារៈសំណង់ជាដើមដែលមានផ្ទុកសារធាតុអាបេស្តូស

あなたは今回の育成就労において、石綿を含む建材等が使用されている建築物等の解体等の業務に従事することがありますが、育成就労実施者は、あなたに健康障害を発生させないための措置を講ずるほか、あなたの健康管理のための健康診断を実施する義務があります。

អ្នកអាចនឹងបំពេញការងារដូចជារុះរើជាដើមនូវសំណង់ជាដើមដែលប្រើប្រាស់សម្ភារៈសំណង់ជាដើមដែលមានផ្ទុកសារធាតុអាបេស្តូស នៅក្នុងការបណ្តុះបណ្តាលនិងការងារលើកនេះ ប៉ុន្តែអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ បន្ថែមពីលើការចាត់វិធានការដើម្បីកុំឲ្យកើតមានផលប៉ះពាល់សុខភាពដល់អ្នក គឺមានកាតព្វកិច្ចអនុវត្តការពិនិត្យសុខភាពដើម្បីគ្រប់គ្រងសុខភាពរបស់អ្នក។

あなたは、自身の健康障害を防止するため、作業手順を守り、保護具を適切に装着するなど、ルールを守って育成就労を行うほか、育成就労実施者が実施する健康診断を受ける義務があります。

ដើម្បីបង្ការផលប៉ះពាល់សុខភាពផ្ទាល់ខ្លួន អ្នកត្រូវចូលរួមការបណ្តុះបណ្តាលនិងការងារដោយគោរពក្បួនច្បាប់ដូចជា គោរពជំហានអនុវត្តការងារ ពាក់ឧបករណ៍ការពារឲ្យសមស្របជាដើម ហើយបន្ថែមពីនេះ ត្រូវមានកាតព្វកិច្ចទទួលការពិនិត្យសុខភាពដែលអនុវត្តដោយអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ។

育成就労の申込みは、これらの内容について十分に理解した上で決定してください。

ក្នុងការដាក់ពាក្យចូលរួមការបណ្តុះបណ្តាលនិងការងារ សូមសម្រេចចិត្តបន្ទាប់ពីយល់ពីខ្លឹមសារទាំងនេះបានគ្រប់គ្រាន់។

## ２　労災保険給付について

## អំពីអត្ថប្រយោជន៍ធានារ៉ាប់រងគ្រោះថ្នាក់ការងារ

石綿にばく露することによって、将来、肺がんや中皮腫等の疾病を発症する可能性があります。

ការប៉ះពាល់សារធាតុអាបេស្តូស អាចនាំឲ្យកើតមានជំងឺដូចជាមហារីកសួត មហារីកនៅស្រទាប់ស្រោមសរីរាង្គ(mesothelioma) ជាដើមទៅអនាគត។

石綿を含む建材等が使用されている建築物等の解体等の業務に従事したことがあり、肺がんや中皮腫等を発症し、それが日本で労働者として従事していたことが原因である（業務上の疾病）と認められた場合には、労災保険給付を受けることができます。

ក្នុងករណីដែលអ្នកធ្លាប់បំពេញការងារដូចជារុះរើជាដើមនូវសំណង់ជាដើមដែលប្រើប្រាស់សម្ភារៈសំណង់ជាដើមដែលមានផ្ទុកសារធាតុអាបេស្តូស ហើយកើតជំងឺមហារីកសួត ឬមហារីកនៅស្រទាប់ស្រោមសរីរាង្គ(mesothelioma) ជាដើម ហើយត្រូវបានទទួលស្គាល់ថាបណ្តាលមកពីបំពេញការងារជានិយោជិត (ជំងឺដោយសារការងារ) នៅប្រទេសជប៉ុន នោះនឹងអាចទទួលបានអត្ថប្រយោជន៍ធានារ៉ាប់រងគ្រោះថ្នាក់ការងារ។

なお、労災保険給付については、あなたが母国に帰国した場合であっても請求することができます。

គួរបញ្ជាក់ថា ចំពោះអត្ថប្រយោជន៍ធានារ៉ាប់រងគ្រោះថ្នាក់ការងារ ទោះបីអ្នកបានត្រលប់ទៅប្រទេសកំណើតហើយក៏ដោយក៏អាចស្នើសុំបានដែរ។

以上の内容について説明しました。
ខ្ញុំបានពន្យល់អំពីខ្លឹមសារខាងលើហើយ។

年　　月　　日
ឆ្នាំ　　ខែ　　ថ្ងៃទី

説明者の氏名
ឈ្មោះអ្នកពន្យល់ ____________________

（申請者（育成就労実施者）との関係　　　　　　　）
(ទំនាក់ទំនងជាមួយនឹងអ្នកស្នើសុំ(អ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ)　　　　　　　)

以上の内容について、上記の説明者から説明を受け、その内容を十分理解しました。
ខ្ញុំបានទទួលការពន្យល់ពីអ្នកពន្យល់ខាងលើអំពីខ្លឹមសារខាងលើ ហើយបានយល់គ្រប់គ្រាន់ពីខ្លឹមសារនោះ។

年　　月　　日
ឆ្នាំ　　ខែ　　ថ្ងៃទី

育成就労外国人になろうとする者／育成就労外国人の署名
ហត្ថលេខារបស់អ្នកដែលនឹងក្លាយជាពលករបរទេសនៃការបណ្តុះបណ្តាលនិងការងារ/ ពលករបរទេសនៃការបណ្តុះបណ្តាលនិងការងារ ____________________